**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ៩ រោច ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មានស្តីពីជំនួបរវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ជាមួយនឹង
# ឯកឧត្តម ហ្គីលប៊ឺត ហុងបូ (Gilbert F. Houngbo) ប្រធានមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម

រសៀលថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឆ្លៀតក្នុងឱកាសដំណើរទស្សនកិច្ចរបស់ឯកឧត្តម **ហ្គីលប៊ឺត ហុងបូ** (Gilbert F. Houngbo) ប្រធានមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (International Fund for Agricultural Development - IFAD) មកកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបឯកឧត្តម **ហ្គីលប៊ឺត ហុងបូ** ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និង IFAD ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម **ហ្គីលប៊ឺត ហុងបូ** និងសហការី ដែលបានអញ្ជើញមកបំពេញបេសកកម្មនៅកម្ពុជា និងបានវាយតម្លៃខ្ពស់ ចំពោះការចូលរួមចំណែកដ៏សំខាន់របស់ IFAD ក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុ ក៏ដូចជាកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយកម្ពុជា នាពេលកន្លងមក ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ដែលកំពុងសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ។ សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថាអាចសម្រេចបានកំណើនខ្ពស់រហូតដល់ ៧,៥% ក្នុងឆ្នាំ ២០១៨ និងតាមការព្យាករណ៍កំណើនសេដ្ឋកិច្ចនេះ នឹងអាចនៅតែសម្រេចបានប្រមាណ ៧% ក្នុងឆ្នាំ ២០១៩ ។ កម្ពុជា កំពុងបន្តដំណើរឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ ២០៥០ ដើម្បីក្លាយទៅជាប្រទេសអភិវឌ្ឍន៍ ។ ឆ្នាំ ២០៣០ ត្រូវបានកំណត់យកជាឆ្នាំគោល ដែលត្រូវសម្រេចឱ្យបាននូវលទ្ធផលជាសារវ័ន្តនៃកំណែទម្រង់សំខាន់ៗ និង ការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ។

ឯកឧត្តម **ហ្គីលប៊ឺត ហុងបូ** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបាននូវកិច្ចអភិវឌ្ឍក្នុងសន្ទុះលឿន និងប្រកបដោយផ្លែផ្កា ។ ឯកឧត្តម ក៏បានរំលឹកឡើងវិញអំពីភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និង IFAD ដែលមានចាប់តាំងពីចុងឆ្នាំ ១៩៩០ មក រួមដំណើរជាមួយគ្នាលើកិច្ចការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ហើយក៏បានគូសបញ្ជាក់ឡើងវិញអំពីការបន្តគាំទ្ររបស់ IFAD លើការអភិវឌ្ឍសេដ្ឋកិច្ចជនបទប្រកបដោយនិរន្តរភាព និងធានាសមធម៌នៃការបែងចែងផលនៃកំណើនជូនប្រជាជននៅទីជនបទ ។ ឯកឧត្តម **ហ្គីលប៊ឺត ហុងបូ** ក៏បានថ្លែងអំណរគុណចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលតែងតែផ្តល់កិច្ចសហការប្រកបដោយភាពជាម្ចាស់ ក្នុងការដឹកនាំការគ្រប់គ្រងគម្រោងក្រោមហិរញ្ញប្បទានរបស់ IFAD នៅកម្ពុជា រហូតសម្រេច

បាននូវជោគជ័យជាច្រើនកន្លងមក ជាពិសេស ក្នុងការគាំទ្ររៀបចំគម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម (Sustainable Assets for Agricultural Markets, Business and Trade - SAAMBAT) ដែលអាចឈានទៅចុះហត្ថលេខានៅត្រីមាសទី ៤ ឆ្នាំ ២០១៩ ខាងមុខនេះ ។ ឯកឧត្តម **ហ្គីលបឺត ហ៊ុងបូ** បានបង្ហាញជំហរថា IFAD មិនត្រឹមតែបន្តផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ IFAD នឹងខិតខំថែមទៀតបំពេញតួនាទីប្រកបដោយបុរេសកម្មក្នុងការទាក់ទាញ និងកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ចូលរួមចំណែកអភិវឌ្ឍនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ IFAD ចំពោះជំហរបន្តគាំទ្រ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល ជាពិសេស វិស័យកសិកម្ម ដែលជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាបានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជូនពរឯកឧត្តម **ហ្គីលបឺត ហ៊ុងបូ** ព្រមទាំងសហការី ឱ្យទទួលបានជោគជ័យក្នុងដំណើរមកទស្សនកិច្ចរបស់ខ្លួននៅកម្ពុជា ។